## គម្រោងអនាម័យគំរូតាមសាលារៀន // ទស្សនាទានៈ

# ការគ្រប់គ្រងអនាម័យពេលមករដូវ

គម្រោងអនាម័យគំរូតាមសាលារៀនថ្នាក់តំបន់ សហការ ជាមួយគម្រោងស្តីពី "អនាម័យប្រកបដោយនិរន្តរភាព" បានបង្កើតទស្សនាទានស្តីពីការគ្រប់គ្រងអនាម័យពេលមករដូវ ដែលជាផ្នែកមួយមានលក្ខណ ស្របទៅនឹងបរិបទវប្បធម៌ និងកិច្ចអន្តរាគមន៍កម្រិតបឋម និងកម្រិតមធ្យម។

### កិច្ចអន្តរាគមន៍កម្រិតបឋម

**ការទទួលបានព័ត៌មានៈ** ឧទាហរណ៍ដូចជា កូនសៀវភៅ ខ្សែវីដេអូ កម្មវិធីអេឡិចត្រូនិច

**បរិក្ខារអនាម័យសម្រាប់ស្ត្រីប្រើប្រាស់ប្រកបដោយផាសុកភាពៈ** បង្គន់អនាម័យត្រូវបែងចែកដាច់ដោយឡែករវាងបុរស និងស្ត្រី មានពន្លឺគ្រប់គ្រាន់ អាចចាក់គន្លឹះបានពីខាងក្នុង មានបរិក្ខារលាងសម្អាតដៃ មានទឹកនិងសាប៊ូ ត្រូវសម្អាតប្រចាំថ្ងៃ មានធុងសំរាមដែលមានគម្រប និងមានមធ្យោបាយសមស្របក្នុងការចោលសំណល់រឹងផ្សេងៗ

**ការទទួលបានសម្ភារគាំទ្រដល់ការគ្រប់គ្រងអនាម័យពេលមករដូវៈ** ឧទាហរណ៍ដូចជា ការផ្តល់សំឡីអនាម័យ ក្នុងពេលបន្ទាន់ ការផ្តល់កំណាត់អនាម័យដែលអាចប្រើប្រាស់ឡើងវិញបាន

**ការដាក់បញ្ចូលទិន្នន័យនៃការគ្រប់គ្រងអនាម័យពេលមករដូវទៅក្នុងប្រព័ន្ធត្រួតពិនិត្យដែលមានស្រាប់ក្នុងវិស័យអប់រំ ( ឧទាហរណ៍ៈ ប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ )**

### កិច្ចអន្តរាគមន៍កម្រិតមធ្យម

ការផ្តល់ថ្នាំបំបាត់ការឈឺចាប់តាមសាលារៀន

ការកសាងសមត្ថភាពសម្រាប់លោកគ្រូ អ្នកគ្រូ និងមន្ត្រីទទួលបន្ទុកសុខភាពសិក្សា

ការជ្រើសរើសគ្រូបង្គោល ទទួលបន្ទុកការគ្រប់គ្រងអនាម័យពេលមករដូវ

ជម្រុញឱ្យមានការចូលរួមពីសិស្សប្រុស និងគ្រូប្រុស

ការអប់រំពីសិស្សម្នាក់ទៅសិស្សម្នាក់ទៀតៈ ឧទាហរណ៍ដូចជាតាមរយៈ ក្រុមប្រឹក្សាសាលា ក្រុមប្រឹក្សាកុមារី

ការផ្តល់បន្ថែមនូវសម្ភារចែករំលែកព័ត៌មាន និងឯកសារពាក់ព័ន្ធក្នុងការអប់រំ

ការគ្រប់គ្រងសំណល់



# "តើមានអ្វីវាស់វែងនូវលទ្ធផលសម្រេចបាន"
# សម្រាប់ ការគ្រប់គ្រងអនាម័យពេលមករដូវ




សូចនាករដោយផ្ទាល់និងប្រយោលស្តីពីការគ្រប់គ្រងអនាម័យពេលមករដូវដែលមានចែងក្នុងក្របខ័ណ្ឌត្រួតពិនិត្យតាមដានកម្មវិធីទឹកស្អាត និងអនាម័យតាមសាលារៀននៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ( SDGs ) ត្រូវបានយកទៅវាស់វែងសម្រាប់សាលានីមួយៗ តាមរយៈប្រព័ន្ធព័ត៌មានគ្រប់គ្រង អប់រំ ( EMIS )

**កម្មវិធីពិនិត្យតាមដានអន្តរជាតិរួម (JMP) ដែលត្រូវបានបង្កើតឡើងដោយអង្គការសុខភាពពិភពលោក (WHO) និងអង្គការមូលនិធិសហប្រជាជាតិសម្រាប់កុមារ (UNICEF) ត្រូវបានប្រើ ដើម្បីវាស់វែងពីកម្រិតនៃសេវាផ្តត់ផ្គង់ទឹកស្អាត និងអនាម័យតាមសាលារៀនធៀបរវាងប្រទេសជាសមាជិកឆ្លើយតបទៅនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ( SDGs )។**

| ទឹកស្អាតសម្រាប់ទទួលទាន | អនាម័យបន្ទោបង់ | អនាម័យខ្លួនប្រាណ |
| --- | --- | --- |
| **សេវាផ្គត់ផ្គង់កម្រិតខ្ពស់** ( ត្រូវបានកំណត់នៅថ្នាក់ជាតិ ) | **សេវាផ្គត់ផ្គង់កម្រិតខ្ពស់** ( ត្រូវបានកំណត់នៅថ្នាក់ជាតិ ) | **សេវាផ្គត់ផ្គង់កម្រិតខ្ពស់** ( ត្រូវបានកំណត់នៅថ្នាក់ជាតិ ) |
| **សេវាផ្គត់ផ្គង់កម្រិតមូលដ្ឋាន** ទឹកសម្រាប់ទទួលទានត្រូវបានយកពីប្រភពទឹកដែលបានកែច្នៃរួច ហើយសាលាកំពុងផ្គត់ផ្គង់ក្នុងអំឡុងពេលនៃការចុះអង្កេត | **សេវាផ្គត់ផ្គង់កម្រិតមូលដ្ឋាន** បរិក្ខារអនាម័យតាមសាលារៀនត្រូវបានកែលម្អដោយមានបែងចែករវាងប្រុសនិងស្រី ហើយអាចប្រើប្រាស់បាន (អាចប្រើប្រាស់បាន មានដំណើរការ និងមានឯកជនភាព ) ក្នុងអំឡុងពេលនៃការចុះអង្កេត | **សេវាផ្គត់ផ្គង់កម្រិតមូលដ្ឋាន** សាលារៀនមានបរិក្ខារលាងសម្អាតដៃព្រមទាំងមានទឹក និងសាប៊ូប្រើប្រាស់ក្នុងអំឡុងពេលនៃការចុះអង្កេត |
| **សេវាផ្គត់ផ្គង់នៅមានកម្រិត** | **សេវាផ្គត់ផ្គង់នៅមានកម្រិត** | **សេវាផ្គត់ផ្គង់នៅមានកម្រិត** |
| **គ្មានសេវាផ្គត់ផ្គង់** | **គ្មានសេវាផ្គត់ផ្គង់** | **គ្មានសេវាផ្គត់ផ្គង់** |

**សេវាផ្គត់ផ្គង់កម្រិតខ្ពស់៖**
- ការទទួលបានព័ត៌មាន
- ភាពស្អាតនៃបង្គន់អនាម័យ
- ទឹកនិងសាប៊ូ ប្រើប្រាស់ក្នុងបន្ទប់ទឹក
- ធុងសំរាមមានគម្របបិទជិត
- យន្តការក្នុងការចោលសំណល់រឹង
- ភ្លើងអគ្គិសនីដំណើរការល្អ
- សម្ភារគ្រប់គ្រងអនាម័យពេលមានរដូវសម្រាប់ប្រើប្រាស់បន្ទាន់

4 QUALITY EDUCATION

**គោលដៅ ៤.a៖** កសាងនិងធ្វើឱ្យប្រសើរឡើងនូវសម្ភារបរិក្ខារអប់រំ ដែលធ្វើឲ្យមានភាពប្រែប្រួលដល់កុមារ អ្នកបាត់បង់សមត្ថភាពពលកម្មនិងយេនឌ័រ និងផ្តល់នូវសុវត្ថិភាព គ្មានអំពើហិង្សា មានបរិស្ថាននៃការសិក្សាប្រកបដោយបរិយាបន្ន និងប្រសិទ្ធិភាពសម្រាប់ប្រជាជនគ្រប់រូប។
**សូចនាករ ៤.a.១៖** សមាមាត្រសាលារៀនដែលមាន ( f ) បរិក្ខារអនាម័យកម្រិតមូលដ្ឋានដែលមានការបែងចែកភេទ និង ( g ) បរិក្ខារលាងសម្អាតដៃកម្រិតមូលដ្ឋាន ( ស្របតាមនិយមន័យសូចនាករទឹកស្អាតនិងអនាម័យ )។

6 CLEAN WATER AND SANITATION

**គោលដៅ ៦.២៖** ត្រឹមឆ្នាំ២០៣០ សម្រេចនូវការទទួលបានគ្រប់គ្រាន់និងសមធម៌នូវអនាម័យ សម្រាប់ប្រជាជនគ្រប់រូប និងបញ្ចប់ការបន្ទោបង់នៅក្រៅបង្គន់ ផ្តោតការយកចិត្តទុកដាក់លើតម្រូវការរបស់ស្ត្រីនិងកុមារី និងប្រជាជនដែលរស់នៅក្នុងស្ថានភាពងាយរងគ្រោះ។
**សូចនាករ៖** សូមមើល ៤.a.១ សម្រាប់សូចនាករទឹកស្អាតនិងអនាម័យតាមសាលារៀន។

SDG 4

**សេវាផ្គត់ផ្គង់កម្រិតមូលដ្ឋាន**
- បរិក្ខារអនាម័យ
  - ដែលមានការបែងចែករវាងប្រុសនិងស្រី
  - ដែលអាចចូលប្រើប្រាស់បាន
  - ដែលមានដំណើរការធម្មតា
  - ដែលមានឯកជនភាព
- បរិក្ខារលាងសម្អាតដៃមានទឹក និងសាប៊ូសម្រាប់ប្រើប្រាស់

## លក្ខណៈនៃបង្គន់អនាម័យមួយដែលស្អាតនិងប្រកបដោយផាសុកភាពសម្រាប់ស្ត្រី






CC BY NC ND